

# ជំពូកទី១០

# បំណិនសង្គម



នៅពេលមនុស្សមានការស្រុះស្រួលគ្នាទៅវិញទៅមក មានន័យថា ពួកគេមាន "បំណិនសង្គម" ល្អ។ មនុស្សអភិវឌ្ឍបំណិនសង្គម ខណៈពេលពួកគេផ្សារភ្ជាប់គ្នាទៅវិញទៅមក រៀនអំពីខ្លួនឯង និងពិចារណាអារម្មណ៍របស់មនុស្សដទៃទៀត។

ការមានបំណិនសង្គមល្អគឺជាការសំខាន់សំរាប់មនុស្សគ្រប់ៗរូប។ បំណិនសង្គមល្អគឺជាការចាំបាច់បំផុតដើម្បីធ្វើឱ្យខ្លួនក្លាយជាចំណែកក្នុងក្រុមណាមួយ ទោះបីជាក្រុមគ្រួសារ ក្រុមមិត្តភក្តិ ឬក្រុមនៃថ្នាក់រៀននៅសាលាក៏ដោយ។

បំណិនសង្គមមិនត្រឹមតែការចេះគួរសមនោះទេ គឺមានចំណុចល្អច្រើនលើសលប់ជាងនេះទៅទៀត។ បំណិនសង្គមល្អនឹងធ្វើឱ្យមនុស្ស :-

- ផ្តល់ និងទទួលការយកចិត្តទុកដាក់ សេចក្តីស្រឡាញ់ ឬជួយគ្នា។
- សំដែងចេញពីសេចក្តីត្រូវការ អារម្មណ៍ និងសិទ្ធិដ៏សមរម្យដែលទទួលយកបាន។
- មានការប្រាស្រ័យទាក់ទងគ្នាយ៉ាងមានប្រសិទ្ធភាព។

ការអភិវឌ្ឍបំណិនសង្គមឱ្យបានល្អ គឺជាការសំខាន់ចំពោះកុមារថ្លង់ ឬមិនអាចស្តាប់ឮល្អ។ លទ្ធភាពសម្របខ្លួននៃកុមារថ្លង់ ឬមិនអាចស្តាប់ឮល្អជាមួយមនុស្សឯទៀត នឹងជួយកាត់បន្ថយភាពឯកោរបស់ពួកគេ។

កុមារថ្លង់ត្រូវតែអភិវឌ្ឍបំណិនសង្គមដោយការសង្កេតមើល និងធ្វើសកម្មភាពរួមគ្នាជាមួយមនុស្សដែលនៅជុំវិញពួកគេ ដូចកុមារស្តាប់ឮអញ្ចឹងដែរ។ ប្រការនេះជួយពួកគេឱ្យចេះគោរពចាស់ទុំ ចេះសុំអនុញ្ញាតប្រើវត្ថុដែលជារបស់នរណាម្នាក់ ឬចេះរងចាំដល់វេនរបស់ខ្លួន ដើម្បីចូលរួមនៅក្នុងសកម្មភាពណាមួយ។



**បំណិនសង្គមល្អ ជួយកុមារឱ្យចេះបង្កើតមិត្តភ័ក្តិ និងផ្សារភ្ជាប់ខ្លួនទៅមនុស្សឯទៀតនៅក្នុងសហគមន៍។**

# របៀបដែលកុមាររៀនបំណិនសង្គម

មនុស្សយើងមិនបានកើតមកជាមួយបំណិនសង្គមឡើយ ។ កាលនៅជាទារក យើងចាប់ផ្តើមរៀនវាយ៉ាងឆាប់រហ័ស នៅពេលដែលយើងបានដឹងពីមនុស្សដទៃទៀត ។ កុមារក៏ដូចជាមនុស្សធំ យើងបន្តរៀននិងប្រើបំណិនទាំងនេះពេញមួយជីវិតរបស់យើង ។

ដំបូង បំណិនសង្គមទាំងនេះ គឺជាការងាយបំផុត ។ ទារករៀនញញឹមតបទៅវិញ ឬ កុមារតូចរៀនផ្លាស់ប្តូរវេនក្នុងពេលលេងល្បែងកំសាន្ត ។ នៅពេលកុមារធំបន្តិច គេត្រូវការអភិវឌ្ឍបំណិនសង្គមបន្ថែមទៀត ដើម្បីសម្របខ្លួនជាមួយមនុស្សឯទៀត ។



**កុមារអាយុ 2 ឆ្នាំ**

- ប្រាប់គេឯង ពេលត្រូវការឱ្យគេជួយ
- លេងក្បែរនឹងកុមារឯទៀត
- ធ្វើត្រាប់តាមអ្នកថែទាំ



**កុមារអាយុ 3 ឆ្នាំ**

- រីករាយជួយកិច្ចការជុំវិញផ្ទះ
- ចូលចិត្តឱ្យមនុស្សសរសើរចំពោះកិច្ចការសាមញ្ញ
- ដឹងពីអារម្មណ៏របស់មនុស្សឯទៀត



**កុមារអាយុ 5 ឆ្នាំ**

- យល់ពីវិន័យ ច្បាប់ទម្លាប់ និងគំនិតដូចជាភាពស្មើគ្នា ត្រូវ និងខុស
- សំដែងចេញអារម្មណ៏ជាច្រើន
- លេងជាមួយកុមារដទៃទៀត



អាកប្បកិរិយា "ត្រឹមត្រូវ" គឺអាស្រ័យលើអាយុរបស់ក្មេង ។ បើសិនជាអ្នករំពឹងទុកច្រើនជាងអ្វីដែលកូនអាចធ្វើបាន អ្នកនិងកូនពិតជាមិនសប្បាយចិត្ត ។ តែបើសិនជាអ្នករំពឹងតិចតួចពីកូន នោះកុមារនឹងមិនចេះបំណិនថ្មីៗ ។ ព័តិមានបន្ថែមស្តីពីពេលណាកុមាររៀនបំណិនថ្មីៗ សូមអានតារាងអភិវឌ្ឍកុមារដែលចាប់ផ្តើមនៅទំព័រ 229 ។

**ព្យាយាមស្វែងយល់ឱ្យកាន់តែច្បាស់ អំពីឥរិយាបថរបស់អ្នកចំពោះលទ្ធភាពរបស់កូនថ្លង់ ។ តើអ្នករំពឹងចង់ឱ្យកូនធ្វើតិចជាងលទ្ធភាពដែលកូនអាចធ្វើបានឬ?**



## កុមាររៀនបំណិនសង្គមជាជំហានៗ

កុមាររៀនបំណិនសង្គមជាជំហានៗ ដូចការអភិវឌ្ឍគ្រប់ប្រភេទដែរ។ ដើម្បីអភិវឌ្ឍបំណិនសង្គម កុមារត្រូវតែដឹងអំពីអារម្មណ៍របស់មនុស្សឯទៀត។ កុមារត្រូវរៀនរបៀបចែករំលែក និងសហការជាមួយមនុស្សឯទៀត។



ដំបូងកុមារម្នាក់លេងក្បែរក្មេងៗឯទៀត។ មានន័យថាក្មេងម្នាក់នេះមានអារម្មណ៍រីករាយបានលេងនៅក្បែរពួកក្មេងៗទាំងនោះ តែតាមពិតក្មេងម្នាក់នេះមិនបានលេងជាមួយពួកក្មេងៗទាំងនោះទេ។



***កាឡាម*ចេះទប់ចិត្តមិនកញ្ឆក់យកស្ករគ្រាប់ពីដៃកុមារឯទៀត ទោះបីជាគេចង់បានវាក៏ដោយ។**

បន្ទាប់មក កុមារនេះចេះលេងជាមួយក្មេងៗឯទៀត។ ក្មេងនេះរៀនចែករំលែកល្បែងលេង និងចេះលេងល្បែងកំសាន្តដែលទាមទារឱ្យគេចេះសហការជាមួយកុមារគ្រប់គ្នា។

ពេលកុមារធំជាងនេះបន្តិច ពួកគេត្រូវតែដឹងអំពីវិន័យ និងអាចរៀនសម្របខ្លួន។

## នៅផ្ទះ

ដំបូង កុមាររៀនអំពីបំណិនសង្គមតាមរយៈការមើលរបៀបដែលឪពុកម្តាយ និងសមាជិកគ្រួសារប្រព្រឹត្តខ្លួនជាមួយមនុស្សឯទៀត។ កុមារធ្វើត្រាប់តាមអ្វីៗដែលមនុស្សឯទៀតធ្វើ និងអ្វីៗដែលពួកគេនិយាយនៅពេលពួកគេចូលរួមធ្វើសកម្មភាពជាមួយគ្នា។







## លេងកំសាន្តជាមួយកុមារឯទៀត

នៅពេលពួកគេលេងកំសាន្ត កុមាររៀនធ្វើតាមទិសដៅណែនាំ សហការ ផ្លាស់ប្តូរវេនគ្នា និងចែករំលែក។ ការលេងកំសាន្តជួយកុមារតូចៗឱ្យយល់អំពីមនោសញ្ចេតនារបស់ខ្លួន មានមោទនភាពចំពោះអ្វីៗដែលពួកគេអាចធ្វើបាន និងអភិវឌ្ឍញាណដឹង ថាខ្លួនគេជាអ្នកណា។

## នៅក្នុងសហគមន៍

នៅខាងក្រៅផ្ទះសម្បែង និងគ្រួសារខ្លួនផ្ទាល់ ក្មេងឃើញពីរបៀបដែលមនុស្សពេញវ័យ និងកុមារធំៗ និយាយលេងកំសាន្ត និងធ្វើការជាមួយគ្នា ។ ប្រការនេះគឺជារបៀបដែលកុមាររៀនផ្សារភ្ជាប់ខ្លួនទៅអ្នកឯទៀតនៅក្រៅគ្រួសាររបស់ខ្លួន ហើយក្នុងពិភពដ៏ធំទូលាយដែលបើកចំហរសំរាប់ពួកគេ ។ កុមាររៀនអនុវត្តឆ្លើយតបខុសគ្នាទៅនឹងស្ថានភាព និងវិធីប្លែកៗក្នុងការធ្វើអ្វីមួយ ។ ពួកគេអភិវឌ្ឍបំណិនសង្គម ខណៈដែលពួកគេរកឃើញចំណុចខ្លាំងនិងខ្សោយរបស់គេផ្ទាល់ ។




## ការពន្លឺ់ចបន្តឱ្យពិបាកថែមទៀតក្នុងការរៀនបំណិនសង្គម

កុមារស្តាប់ឮរៀនយ៉ាងច្រើនពីព្រឹត្តិការណ៍ទាំងឡាយដោយការស្តាប់នូវអ្វីៗដែលកើតមានបន្តនៅជុំវិញខ្លួន ។ បំណិនសង្គមដែលពួកគេចេះភាគច្រើន គឺមិនបានបង្រៀនត្រង់ៗដល់ពួកគេនោះទេ តែបំណិនទាំងនោះបានអភិវឌ្ឍខណៈដែលពួកគេស្តាប់ឮមនុស្សឯទៀតនិយាយគ្នា ។ កុមារមិនអាចស្តាប់ឮ បាត់បង់នូវព័ត៌មាននេះមួយភាគធំ ។

ជាញឹកញាប់កុមារមិនអាចស្តាប់ឮល្អរកឃើញថាគេមានការលំបាករៀនរបៀបសម្របខ្លួនជាមួយមនុស្សម្នាជាងកុមារឯទៀត ។ ក្មេងនេះមិនយល់ពីអាកប្បកិរិយាដែលខ្លួនមើលឃើញ និងហេតុផលអ្វីដែលធ្វើឱ្យមនុស្សមានអាកប្បកិរិយាបែបនោះឡើយ ។




***រ៉ាម៉ានី* ចង់បានចេកមួយផ្លែ តែនាងមិនដឹងថាមុនដំបូងម្តាយនាងត្រូវទិញវាសិន ។**

នេះជាការពិត ជាពិសេសពេលដែលកុមារថ្លង់ និងឪពុកម្តាយមិនអាចប្រាស្រ័យទាក់ទងគ្នាបានល្អ ។ នៅពេលកុមារថ្លង់ប្រព្រឹត្តពុំគប្បី វាប្រហែលជាពិបាកនិយាយពន្យល់ក្មេងថា តើគេគួរប្រព្រឹត្តខ្លួនបែបណាឱ្យសមរម្យ ។ កុមារអាចទៅជាធុញទ្រាន់ និងសំដែងអាកប្បកិរិយាពុំគប្បីកាន់តែខ្លាំងឡើង ។ កុមារដែលសំដែងអាកប្បកិរិយាមិនល្អកាន់តែច្រើន តែងតែត្រូវទុកចោលម្នាក់ឯង ហើយគ្មានអ្នកណាអើពើ ។

កុមារថ្លង់ត្រូវការជួយបន្ថែមទៀតដើម្បីរៀនរបៀបប្រាស្រ័យទាក់ទង សហការជាមួយមនុស្សឯទៀត និងការសម្របខ្លួន ។

## របៀបគ្រប់គ្រងអាកប្បកិរិយាកូនរបស់អ្នក

ភាពថ្លង់មិនមែនជាមូលហេតុបណ្តាលឱ្យមានអាកប្បកិរិយាអាក្រក់ទេ ទោះបីវាហាក់ដូចជាដើមហេតុក៏ដោយ ។ កុមារម្នាក់ដែលមិនអាចស្តាប់ឮល្អប្រាស្រ័យទាក់ទងជាចំបង តាមរយៈអាកប្បកិរិយារបស់ខ្លួនដូចដែលកុមារស្តាប់ឮម្នាក់មិនទាន់បានអភិវឌ្ឍបំណិនប្រាស្រ័យទាក់ទងអញ្ចឹងដែរ ។

រៀនសំគាល់មើលសញ្ញាដែលប្រាប់អ្នកថា វិបត្តិអាកប្បកិរិយា គឺបម្រុងនឹងកើតឡើង :-




**បើសិនជា*ប៉ូឡូ*អាចស្តាប់ឮ គេនឹងបានដឹងថា ពួកគេត្រូវចេញទៅផ្ទះក្នុងពេលឆាប់ៗ តាមរយៈការនិយាយគ្នារបស់ម្តាយ និងជីដូន ។**

**គេនឹងអាចត្រៀមខ្លួនបានប្រសើរចំពោះអ្វីដែលនឹងកើតឡើងបន្ទាប់ទៀត ។**

ដោយសារតែ***ប៉ូឡូ***មិនអាចស្តាប់ឮល្អ ***ប៉ូឡូ***មានការភ្ញាក់ផ្អើលនៅពេលដែលជីដូនប្រាប់គេថា ពួកគេត្រូវទៅផ្ទះ ។ គ្រប់ពេលវេលាទាំងអស់ កុមារថ្លង់តែងមានបទពិសោធន៏ភ្ញាក់ផ្អើលដូច***ប៉ូឡូ***អញ្ចឹងដែរ ។

ឪពុកម្តាយត្រូវតែផ្តោតការយកចិត្តទុកដាក់ទៅលើអាប្បកិរិយារបស់កុមារថ្លង់ ឬមិនអាចស្តាប់ឮល្អ ថាតើក្មេងមានអាកប្បកិរិយាយ៉ាងដូចម្តេច ។ វាទាមទារការអត់ធ្មត់ដើម្បីយល់ពីអ្វីដែលកូនកំពុងប្រាស្រ័យទាក់ទងជាមួយអ្នក និងរៀនរបៀបប្រាស្រ័យទាក់ទងនឹងកូនដោយផ្អែកតាមអ្វីៗដែលអ្នកបានសង្កេតមទុកជាមុន ។

កុមារស្តាប់ឮរៀនការសម្របខ្លួនបានងាយស្រួល និងនៅអាយុតិចជាងកុមារមិនអាចស្តាប់ឮល្អ ។ មួយរយៈក្រោយមកកុមារឆ្លើយថា "ទេ" ចំពោះអ្វីដែលឪពុកម្តាយចង់ឱ្យពួកគេធ្វើ ។ អាកប្បកិរិយាទាំងនេះ អាចជាការធុញទ្រាន់យ៉ាងខ្លាំងចំពោះក្រុមគ្រួសាររបស់កុមារ ប៉ុន្តែអាកប្បកិរិយាទាំងនោះគឺជារឿងធម្មតា ហើយវានឹងសាបរលាបទៅវិញនៅពេលណាដែលកុមារចេះទប់ចិត្តខ្លួនឯងបានល្អប្រសើរ ។

វាជាការលំបាកយ៉ាងខ្លាំងសំរាប់កុមារមិនអាចស្តាប់ឮល្អរៀនអំពីការទប់ចិត្ត ។ នៅពេលមនុស្សទាំងឡាយមិនអាចប្រាស្រ័យទាក់ទងជាមួយកុមារថ្លង់ កុមារថ្លង់អាចទៅជាធុញទ្រាន់ រកាំចិត្ត ឬខឹងសម្បារ ។ ពួកគេមិនអាចយល់ថា ហេតុអ្វីគេត្រូវតែធ្វើទង្វើនោះ ឬក៏អ្វីខ្លះកំពុងកើតឡើងជុំវិញពួកគេ ។



## ព្យាយាមបង្ការកុំឱ្យបញ្ហាកើតឡើង

នៅពេលកុមារសំដែងអាកប្បកិរិយាយ៉ាងអាក្រក់ៗ ចូរចាប់ផ្ដើមសួរខ្លួនអ្នកថា "តើកូនកំពុងព្យាយាមប្រាប់ខ្ញុំអំពីអ្វី?" "តើកូនខ្ញុំត្រូវការអ្វី?"។ ត្រូវចាំថាអាកប្បកិរិយារបស់កូនអ្នក គឺជាវិធីមួយក្នុងចំណោមវិធីជាច្រើនដែលកូនប្រាស្រ័យទាក់ទងជាមួយអ្នក។ ជាញឹកញាប់ កូនតែងប្រាប់អ្នកអំពីអ្វីមួយតាមរយៈអាកប្បកិរិយារបស់គេ ពីព្រោះកូនមិនអាចធ្វើការប្រាស្រ័យទាក់ទងជាពាក្យសម្ដី ឬជាសញ្ញាឡើយ ។

បើសិនជាអ្នកយល់ពីមូលហេតុដែលបង្កទៅជាវិបត្តិអាកប្បកិរិយា នោះអ្នកប្រហែលជាអាចចៀសវាងបញ្ហាបានមួយកំរិត ។ កូនរបស់អ្នកអាច :-



- ត្រូវការឱ្យយកចិត្តទុកដាក់ ។ ក្មេងអាចដឹងថា បើសិនជាគេសំដែងអាកប្បកិរិយាអាក្រក់ៗ គេពិតជាទទួលបានការយកចិត្តទុកដាក់ថែមទៀត ។
- អស់កម្លាំង ឃ្លាន ឬខ្លាចអ្វីមួយ ។
- មិនយល់ពីអ្វីដែលអ្នកចង់បាន ។ ឬកុមារចង់បានអ្វីមួយ តែមិនអាចប្រាស្រ័យទាក់ទងដើម្បីឱ្យអ្នកយល់បាន ។
- ត្រូវបានកុមារ ឬមនុស្សធំណាម្នាក់បន្ទុះបង្អាប់ ឬប្រព្រឹត្តអំពើអាក្រក់មកលើខ្លួន ។
- ធ្វើត្រាប់តាមអាកប្បកិរិយាក្មេងណាម្នាក់ទៀត ។
- មិនបានឈានដល់ការរំពឹងទុករបស់អ្នក ។ ឬកូនអាចចចេសរឹងរូសលើការដាក់កំហិតរបស់អ្នក ឬក៏កូនបង្ហាញអ្នកថាខ្លួនគេមិនចង់ធ្វើអ្វី ដែលអ្នកចង់ឱ្យគេធ្វើនោះទេ ។

ទោះបីជាអ្នកអាចយល់ពីមូលហេតុបណ្ដាលឱ្យកូនរកាំចិត្តក៏ដោយ ក៏នៅមានពេលដែលកូនត្រូវរកាំចិត្តចៀសមិនរួច ទោះបីជាអ្នកខំល្បួងលោមយ៉ាងណាក្ដី ។ តែបើអ្នកអាចឃើញថា អាកប្បកិរិយារបស់កូនគឺជាវិធីដែលកូនធ្វើការប្រាស្រ័យទាក់ទងជាមួយអ្នក នោះអ្នកប្រហែលជាអាចដោះស្រាយតម្រូវការរបស់កូនបានមុនពេលវាក្លាយជាបញ្ហា ។

## របៀបដាក់កំហិតកូន

ទោះបីជាពេលកូនមានអាកប្បកិរិយាល្អក៏ដោយ គង់តែនៅមានពេលណាមួយអ្នកត្រូវប្រាប់កូនថា "ទេ" និងដាក់កំហិតលើអាកប្បកិរិយារបស់កុមារ ។ ប្រការនេះ ប្រហែលជារក្សាសុវត្ថិភាពរបស់កូន ឬព្រោះតែកូនសំដែងអាកប្បកិរិយាមិនគប្បី ឬក៏កូនចង់ធ្វើអ្វីមួយដែលអ្នកមិនអនុញ្ញាត ។ កុមារមានអាយុខុសៗគ្នា ត្រូវការការដាក់កំហិតផ្សេងៗពីគ្នាដែរ ។ ការដាក់កំហិតរបស់អ្នកនឹងផ្លាស់ប្ដូរទៅតាមពេលវេលា ខណៈដែលកូនធំបន្តិចម្ដងៗ និងរៀនកាន់តែច្រើនទៀតអំពីព្រឹត្តិការណ៍ទាំងឡាយដែលនៅជុំវិញ ។

ជួនកាលកូនមិនយល់ពីអ្វីដែលអ្នកចង់បាន ដោយសារតែកូនស្ដាប់មិនឮល្អ ។ នៅពេលអ្នកនិយាយថា "ទេ" ឬប្រាប់កូននូវអ្វីដែលអ្នកចង់ឱ្យកូនធ្វើ អ្នកអាចមិនទាន់មានបំណិនប្រាស្រ័យទាក់ទងគ្រប់គ្រាន់ ដើម្បីពន្យល់កូនឱ្យយល់ ។ អ្នកអាចគិតថា កូនមិនអើពើនឹងអ្នក ឬប្រព្រឹត្តអំពើពុំគប្បី តែតាមការពិតនោះ កូនមិនយល់នូវអ្វីដែលអ្នកចង់បាន ឬចង់ឱ្យគេធ្វើ ។




***អានីតា*មិនយល់នូវអ្វីដែលឪពុកនាងប្រាប់ឡើយ ។**

នៅពេលដែលអ្នកចង់ដាក់កំហិតលើអាកប្បកិរិយារបស់ក្មេង ឬចង់ផ្លាស់ប្តូរអ្វីមួយដែលក្មេងកំពុងធ្វើ :-

1. ប្រាប់កូនអំពីប្រការនោះ ។ សូមគិតឱ្យបានល្អិតល្អន់មុនពេលអ្នកនិយាយថា "ទេ" ។ នៅពេលអ្នកនិយាយថា "ទេ" អ្នកគួរតែនិយាយឱ្យបានម៉ឺងម៉ាត់ ។ បើអ្នកធ្វើឱ្យកូនផ្លាស់ប្តូរគំនិតរបស់អ្នក ព្រោះតែអាកប្បកិរិយាអាក្រក់របស់គេ ពេលនោះកូននឹងដឹងថាគេត្រូវតែប្រព្រឹត្តពុំគប្បីដើម្បីទទួលបានអ្វីមួយតាមទំនើងចិត្ត ។




កាលដែលអ្នកប្រាប់កូនថាគេមិនអាចធ្វើអ្វីមួយ ឬមិនបានរបស់អ្វីមួយនោះ អ្នកមិនគួរផ្លាស់ប្តូរគំនិត គ្រាន់តែលួងលោមឱ្យកូនឈប់យំបានហើយ ។

2. បង្ហាញកូនថា អ្នកចង់មានន័យយ៉ាងម៉េច ។




3. **ប្រើរូបភាព** ដើម្បីធ្វើឱ្យសំណើនោះកាន់តែច្បាស់ ។




**រូបភាពពិតជាមានប្រយោជន៍ណាស់ សំរាប់អ្វីៗដែលពិបាកប្រាស្រ័យទាក់ទង ដូចជារបៀបដែលសកម្មភាពរបស់កុមារធ្វើឱ្យប៉ះពាល់ដល់មនុស្សដទៃ ។**

4. **ជួយ**កុមារធ្វើកិច្ចការនោះ ខណៈដែលអ្នកប្រាប់កុមារឱ្យធ្វើ ។

បើសិនជាកុមារថ្លង់មានបញ្ហាមិនយល់អ្វីដែលអ្នកបានស្នើឡើង អ្នកត្រូវធ្វើកិច្ចការនោះបង្ហាញឱ្យកុមារឃើញ ដើម្បីបញ្ជាក់ថាអ្នកចង់មានន័យយ៉ាងម៉េច ។

## វិធីនានាដើម្បីគ្រប់គ្រងអាកប្បកិរិយាដែលមិនមានដំណើរការល្អ

ក្រុមគ្រួសារទាំងឡាយដែលមានកូនថ្លង់ ប្រហែលជាបានជួបប្រទះនូវវិបត្តិអាកប្បកិរិយានានា ដែលពួកគេមិនដឹងអំពីរបៀបដោះស្រាយ ។ ពេលខ្លះពួកគេប្រើដំណោះស្រាយដែលមានប្រសិទ្ធភាពតែមួយភ្លែត ទោះបីជាវិធីទាំងនោះមិនជួយឱ្យកុមាររៀនធ្វើអាកប្បកិរិយាល្អក៏ដោយ ។ ឧទាហរណ៍ទាំងនេះ ជាករណីដែលមិនមានដំណើរការល្អ :-



- ការបញ្ជារដោយគ្មានការពន្យល់អំពីហេតុផលនៃបញ្ជាដល់កុមារ ឬវាមានន័យអ្វីខ្លះ ។ បែបនេះគឺរារាំងកុមារមិនឱ្យធ្វើការសំរេចចិត្តល្អៗដោយខ្លួនឯង ។
- ការដាក់ទណ្ឌកម្មកុមារថ្លង់ច្រើនជាងកុមារដទៃ ។ ការវាយដំលើរាងកាយអាចធ្វើឱ្យកុមារធ្លាក់ទឹកចិត្ត ឬមានហឹង្សាក្នុងចិត្ត ។



- បណ្តែតបណ្តោយឱ្យអាកប្បកិរិយាពុំគប្បីរបស់កុមារមិនអាចស្តាប់ឮល្អ ចេះតែកើតមានជាបន្តដោយពុំមានការកែតម្រូវវា ។ ប្រការនេះធ្វើឱ្យកុមារកាន់តែដាច់ឆ្ងាយពីសង្គម ។
- ទុកឱ្យកុមារមិនអាចស្តាប់ឮល្អនៅផ្ទះច្រើនជាងកុមារឯទៀត ។ ប្រការនេះបានរារាំងដល់ការអភិវឌ្ឍផ្នែកសង្គមរបស់កុមារមិនឱ្យលូតលាស់ ។

ទោះបីជាវិធីសាស្រ្តទាំងអស់នេះទំនងជាមានប្រសិទ្ធភាពមួយភ្លែត តែវាមិនបានជួយកុមាររៀនរបៀបប្រព្រឹត្តខ្លួនឱ្យល្អ ឬរបៀបប្រាស្រ័យទាក់ទងជាមួយមនុស្សឯទៀតឡើយ ។

ឪពុកម្តាយគ្រប់រូបចង់ឱ្យកូនប្រព្រឹត្តខ្លួនសមរម្យ និងធំដឹងក្តីឡើងក្លាយជាសមាជិកដែលចុះចំណោមក្នុងសហគមន៍ ។ ការចេះទប់ចិត្តរបស់អ្នកអាចជាគំរូ សំរាប់ឱ្យកូនអភិវឌ្ឍការទប់ចិត្តរបស់គេផងដែរ ។ បង្ហាញកូននូវប្រភេទនៃអាកប្បកិរិយារបស់បុគ្គលណាម្នាក់ដែលជាមនុស្សល្អក្នុងការរស់នៅជាមួយ ។

### ▶ របៀបជួយកូនឱ្យមានចិត្តស្ងប់ពេលកូនប្រព្រឹត្តអាក្រក់

នៅពេលកូនអ្នកប្រព្រឹត្តអាក្រក់ យកកូនទៅកន្លែងផ្សេងមួយ ហើយឱ្យកូនអង្គុយចំនួនប្រាំនាទី (ប្រើពេលខ្លីជាងនេះចំពោះក្មេងតូចៗ) ។ បើកុមារព្យាយាមចេញពីកន្លែងមុនពេលកំណត់ សូមចាប់ផ្តើមកំណត់ម៉ោងសាជាថ្មីម្តងទៀត ។ កុំទុកក្មេងឱ្យនៅម្នាក់ឯង ។ អ្នកអាចប្រើ "ទណ្ឌកម្មពេលខ្លី" ធ្វើបែបនេះ គឺដើម្បីទុកពេលឱ្យកូនគិតពិចារណាអំពីអាកប្បកិរិយា និងរបៀបដែលគេអាចប្រព្រឹត្តខ្លួនឱ្យប្រសើរឡើង ។ "ទណ្ឌកម្មពេលខ្លី" ក៏ទុកពេលឱ្យអ្នកបានរំសាយចិត្តនៅពេលដែលអ្នកតឹងតែងក្នុងចិត្ត ឬរកាំចិត្តផងដែរ ។



មុនពេលកំណត់ "ទណ្ឌកម្មពេលខ្លី" ចូរកាន់ដៃកូនឱ្យមាំ និងពន្យល់ណែនាំកូននូវរបៀបដែលអ្នកចង់ឱ្យកូនប្រព្រឹត្តខ្លួន។ ពេលកូនស្ងប់ចិត្តបន្តិច ចូរប្រាស្រ័យទាក់ទងពន្យល់ឱ្យកូនដឹងថា ហេតុអ្វីបានជាគេត្រូវការ "ទណ្ឌកម្មពេលខ្លី" និងអំពីរបៀបដែលការប្រព្រឹត្តខ្លួនរបស់កូនធ្វើឱ្យប៉ះពាល់ដល់មនុស្សឯទៀត។ ចូររំលឹកឱ្យកូនដឹងថាអ្នកចូលចិត្តគេ ប៉ុន្តែអ្នកមិនចូលចិត្តទង្វើដែលគេបានប្រព្រឹត្តនោះទេ។ លើកទឹកចិត្តកូនឱ្យធ្វើសញ្ញា ឬនិយាយប្រាប់អំពីអ្វីដែលបានកើតឡើង និងហេតុអ្វី ហើយវាយ៉ាងម៉េចបានជាគេឆ្លើយតបយ៉ាងចម្លែកបែបនេះ។ អ្នកត្រូវជួយឱ្យកូនយល់ថា ហេតុអ្វីបានជាកូនត្រូវការ "ទណ្ឌកម្មពេលខ្លី" ដូច្នេះ។




### អ្វីៗដែលត្រូវធ្វើ បើសិនជាកូនខឹងក្រញ៉ូងក្រញ៉ាំង (ឬ យំឡាំប៉ា)

ដូចកុមារតូចៗជាច្រើនទៀតដែរ ការខឹងសម្បាររបស់កូនអ្នកអាចក្លាយជា "យំឡាំប៉ា ឬខឹងក្រញ៉ូងក្រញ៉ាំងខ្លាំង"។ ខឹងក្រញ៉ូងក្រញ៉ាំង គឺនៅពេលដែលកូនក្រពុលមុខទប់ចិត្តលែងកើត ហើយស្រែក ធាក់ វាយគេឯង ឬស្រែកយំយ៉ាងខ្លាំង។ តាមធម្មតាកុមារដែលមិនអាចប្រាស្រ័យទាក់ទងបានដោយងាយស្រួល ច្រើនតែខឹងក្រញ៉ូងក្រញ៉ាំងជាងកុមារឯទៀត ហើយវាប្រហែលជាពិបាកបន្ធូរបន្ថយកំហឹងរបស់ពួកគេយ៉ាងខ្លាំង។ ជាការសំខាន់ សំរាប់អ្នកត្រូវទ្រាំសង្កត់ចិត្តឱ្យស្ងប់ឱ្យបានច្រើនតាមដែលអ្នកអាចធ្វើបាន។ ចូរទុកពេលពីរបីនាទី ដើម្បីសំរេចចិត្តថាត្រូវធ្វើអ្វីទៀត។ នេះជាវិធីខ្លះៗដែលមានប្រយោជន៍សំរាប់ទប់ទល់នឹងការខឹងក្រញ៉ូងក្រញ៉ាំងរបស់កុមារ :-

- កុំព្យាយាមពន្យល់កូន នៅពេលកូនទប់ចិត្តលែងកើត។ ពេលនេះ មិនមែនជាពេលល្អសំរាប់ការពិភាក្សាគ្នាទេ។
- កុំឆ្លើយតបទៅនឹងសម្រែក និងការទាត់ធាក់របស់កូន តែមិនត្រូវទុកកូនឱ្យនៅម្នាក់ឯងឡើយ។ អាកប្បកិរិយារបស់កូនអាចធ្វើឱ្យគេខ្លាចខ្លួនឯង ហើយត្រូវការឱ្យអ្នកនៅក្បែរគ្រាន់ជាបង្អែកកក់ក្តៅ។
- កុំវាយតប់ ក្តិច កញ្ឆក់កញ្ឆែង ឬស្រែកដាក់កូនឱ្យសោះ វាធ្វើឱ្យក្មេងកាន់តែខឹងក្រពុលមុខខ្លាំង តែដាច់ខាតកុំឱ្យកូនវាយអ្នក។ អ្នកអាចឱបកូន នេះគឺគ្រាន់តែការពារកូនកុំឱ្យបង្កគ្រោះថ្នាក់ដល់ខ្លួនគេ ដល់អ្នក ឬបំផ្លាញវត្ថុចោលតែប៉ុណ្ណោះ។
- ព្យាយាមបន្ធូរចិត្តកូនក្នុងពេលកំពុងខឹងក្រញ៉ូងក្រញ៉ាំង។ ឧទាហរណ៍ បើកូនស្រែកដោយសារតែអ្នកបានយកអ្វីមួយចេញពីគេ អ្នកអាចសាកល្បងឱ្យអ្វីមួយទៀតដែលកូនចង់បាន ឬបង្ហាញកូនអំពីអ្វីមួយដែលខុសពីធម្មតា។ ប្រការនេះមានប្រសិទ្ធភាពយ៉ាងប្រសើរជាមួយកុមារតូចៗ។



**ចូរយកកុមារដែលខឹងឡាំប៉ាចេញឱ្យឆ្ងាយពីកន្លែងកើតហេតុ បើសិនជាអ្នកអាចធ្វើបាន។**

បើសិនជាការយំឡូឡាំប៉ាស្ថិតនៅក្នុងកំហិតព្រំដែនដែលអ្នកបានកំណត់ កុំបណ្តោយឱ្យអាកប្បកិរិយារបស់កូនផ្លាស់ប្តូរកំហិតដែនកំណត់នោះ ។ បើសិនជាអ្នកបណ្តោយតាមអាកប្បកិរិយារបស់កូន កូននឹងយល់ថាគេអាចធ្វើអ្វីតាមទំនើងចិត្តដោយសារការខឹងក្រញ៉ុងក្រញ៉ាំងនេះ ។

## នៅពេលកូនមានអាកប្បកិរិយាពុំគប្បី ឬខឹងឡូឡាំប៉ានៅទីសាធារណៈ



បើសិនជាកុមារសំដែងអាកប្បកិរិយាអាក្រក់នៅទីសាធារណៈ លើកក្មេងពឡើង បើសិនជាអ្នកអាចធ្វើបាន ហើយយកក្មេងចេញពីស្ថានភាពនោះ ។ ព្យាយាមធ្វើចិត្តឱ្យស្ងប់ និងមិនខឹងសម្បារ ។ ចូរនាំក្មេងចេញទៅខាងក្រៅហាង និងទៅឱ្យឆ្ងាយពីផ្សារ ឬឱ្យឆ្ងាយពីកន្លែងដែលបញ្ហាបានកើតឡើង ។ បើសិនជាអ្នកអាច ចូររកកន្លែងស្ងាត់មួយសំរាប់ឱ្យកូនរំសាយចិត្ត ។ បើសិនជាចាំបាច់ ឱ្យនរណាម្នាក់នៅជាមួយក្មេង ខណៈដែលអ្នកទៅបញ្ចប់កិច្ចការដែលត្រូវធ្វើ ។

ការទុកកូនឱ្យនៅផ្ទះហាក់ដូចជាងាយស្រួលជាងការព្រួយបារម្ភពីបញ្ហាអាកប្បកិរិយារបស់កូននៅតាមទីសាធារណៈ ។ ប៉ុន្តែការរៀនអំពីរបៀបសម្របអាកប្បកិរិយានៅតាមទីសាធារណៈ និងក្លាយជាចំណែកមួយនៃសហគមន៏របស់ខ្លួន គឺសំខាន់ចំពោះកុមារគ្រប់រូប ។

## សកម្មភាពរបស់យើង គឺជាគ្រូបង្រៀនដ៏មានអំណាច

ដូចនៅក្នុងគ្រួសារឯទៀតអញ្ចឹងដែរ ជាការសំខាន់សំរាប់គ្រួសារដែលមានកូនថ្លង់ម្នាក់ ត្រូវកំណត់យកគំរូល្អៗមកប្រើប្រាស់ជាមួយកូន ។ គ្រួសារនេះត្រូវតែប្រព្រឹត្តនូវទង្វើសមរម្យទាំងឡាយណា ដែលពួកគេចង់ឱ្យកូនថ្លង់ប្រព្រឹត្តអញ្ចឹងដែរ ហើយពន្យល់ណែនាំកូនអំពីអាកប្បកិរិយាបែបណាដែលពួកគេពេញចិត្ត ។ ប៉ុន្តែ វាមិនមែនជាការងាយស្រួលក្នុងការកំណត់គំរូល្អៗ និងលើកទឹកចិត្តកុមារឱ្យមានអាកប្បកិរិយាសមរម្យនោះទេ ។




ជាញឹកញាប់ ការចិញ្ចឹមកុមារតូចៗអាចជាការតឹងតែងក្នុងចិត្ត ។ នៅពេលដែលការប្រាស្រ័យទាក់ទងមានការលំបាក នោះវាកាន់តែពិបាកខ្លាំងទៀតដើម្បីបង្រៀនក្មេងឱ្យចេះរបៀបប្រព្រឹត្តខ្លួនល្អ ។ ឪពុកម្តាយ និងអ្នកថែទាំឯទៀត អាចទៅជាតឹងតែងក្នុងចិត្តជាមួយកុមារ ហើយវាយដំ ឬកញ្ឆក់កញ្ចែងកុមារថ្លង់ច្រើនជាងកុមារស្តាប់ឮ ដោយសារការប្រាស្រ័យទាក់ទងជាមួយកូនថ្លង់មានការលំបាកច្រើនពេក ។ សូមអានជំពូកទី14 សំរាប់ព័ត៌មានបន្ថែមដើម្បីជួយដល់ឪពុកម្តាយ និងអ្នកថែទាំ ។

វាអាចជាការពិបាកសំរាប់មនុស្សផ្លាស់ប្តូរទម្លាប់ប្រៀនប្រដៅកុមារ ។ មនុស្សស្ទើរតែទាំងអស់ប្រដៅកុមារទៅតាមទម្លាប់ ដែលពួកគេធ្លាប់បានទទួលការប្រៀនប្រដៅកាលពីកុមារភាព ។ ប៉ុន្តែនៅពេលដែលយើងដោះស្រាយចិត្តតឹងតែងរបស់យើងដោយអហឹង្សា យើងបានបញ្ជូនសារដ៏មានអំណាចឱ្យកូនដឹងថា ពួកគេក៏ត្រូវតែដោះស្រាយភាពតឹងតែងដោយអហឹង្សាអញ្ចឹងដែរ ។ ករណីនេះ គឺជារឿងដែលឪពុកម្តាយមួយក្រុមបានធ្វើការដើម្បីផ្លាស់ប្តូរទម្លាប់ប្រៀនប្រដៅកូនរបស់ពួកគេ :-

**ឪពុកម្តាយនៅប្រទេសម៉ិចស៊ិក បានរកឃើញវិធីផ្សេងទៀតដើម្បីអប់រំទូន្មានដល់កូនៗ**

កម្មវិធីសាលាមត្តេយ្យសំរាប់កុមារថ្លង់នៅតំបន់អូសាកានៃប្រទេសម៉ិចស៊ិក បានចាប់ផ្តើមឡើងដោយភ្នាក់ងារសង្គមកិច្ចម្នាក់ និងគ្រូបង្រៀនម្នាក់។ រៀងរាល់ថ្ងៃឪពុកម្តាយតែងមកសាលារៀនជាមួយកូនៗ។ ឪពុកម្តាយបានចូលរួមក្នុងសកម្មភាពនានាជាមួយកូនៗ ហើយពួកគាត់ជួយគាំទ្រគ្នាទៅវិញទៅមក។

មួយរយៈក្រោយមក ឪពុកម្តាយចាប់ផ្តើមសំគាល់ឃើញថា វាកើតឡើងញឹកញាប់ណាស់ដែលពួកគាត់តែងវាយដំ និងកញ្ឆក់កញ្ឆែងកូនៗ។ ពួកគាត់បានប្រជុំពិភាក្សាគ្នាជាមួយភ្នាក់ងារសង្គមកិច្ច ហើយសំរេចចិត្តថាពួកគាត់ចង់ស្វែងរកវិធីផ្សេងទៀតដើម្បីប្រៀនប្រដៅកូន។ ភ្នាក់ងារសង្គមកិច្ចបានពន្យល់អំពី "ទណ្ឌកម្មពេលខ្លី" ដោយយកកុមារចេញពីស្ថានភាពបញ្ហា ហើយឱ្យកូនអង្គុយស្ងៀមស្ងាត់មួយសន្ទុះ (ពីរបីនាទី)។

ឪពុកម្តាយបានសំរេចចិត្តថា បើសិនជាពួកគាត់ផាកពិន័យខ្លួនឯងជាថវិកាពីរបីផេសូរ (លុយម៉ិចស៊ិក) រៀងរាល់ពេលដែលពួកគាត់វាយដំ ឬកញ្ឆក់កញ្ឆែងកូនៗ នោះវានឹងជួយពួកគាត់ឱ្យឈប់វាយដំ ឬកញ្ឆក់កញ្ឆែងកូនៗ។ ពួកគាត់យកកំប៉ុងទទេរមួយដាក់លើធ្នើរ សំរាប់ទុកដាក់លុយពិន័យ។ មុនដំបូងឪពុកម្តាយស្ទើរតែទាំងអស់ពិន័យលុយចូលក្នុងកំប៉ុងរាល់ថ្ងៃ។ តែការពិន័យនេះជួយឱ្យពួកគាត់សញ្ជឹងគិត មុនពេលពួកគាត់លើកដៃវាយ ឬកញ្ឆក់កញ្ឆែងកូន។




ខណៈដែលពួកគាត់ធ្វើការសាកល្បងវិធីសាស្ត្រថ្មីៗ ហើយការប្រាស្រ័យទាក់ទងរបស់ពួកគាត់ក៏បានប្រសើរឡើង ឪពុកម្តាយទាំងនេះបានសំគាល់ឃើញថា កូនៗរបស់គាត់មានអាកប្បកិរិយាល្អប្រសើរជាងមុន។ វាហាក់ដូចជាមិនងាយស្រួលសោះ កាលពីពេលចាប់ផ្តើមផ្លាស់ប្តូរទម្លាប់ដែលពួកគាត់ទូន្មានកូនៗ ប៉ុន្តែឥឡូវនេះពួកគាត់ស្ទើរតែលែងវាយដំ ឬកញ្ឆក់កញ្ឆែងកូនទាំងស្រុង។

## របៀបលើកទឹកចិត្តដល់ការអភិវឌ្ឍសកម្មភាពសង្គមរបស់កុមារ




ជួយកូនអ្នកឱ្យបានស្គាល់មនុស្សថ្លង់ពេញវ័យ ឬ មនុស្សពេញវ័យដែលមិនអាចស្តាប់ឮ ។ ប្រការនេះជួយកុមារឱ្យដឹងថា មនុស្សពេញវ័យដែលមិនអាចស្តាប់ឮ ក៏នៅតែជាមនុស្សមានជោគជ័យក្នុងជីវិតដែរ ហើយជួយឱ្យក្មេងកសាងសេចក្តីទុកចិត្ត និងផ្តល់តម្លៃឱ្យខ្លួនឯង ។ បើកុមារបានឃើញពួកគេធំទាំងនោះកំពុងសហការគ្នា សួរសំណួរ ឆ្លើយតប និងបង្ហាញអារម្មណ៍ នោះកុមារនឹងរៀនពីវិន័យសង្គម និងអភិវឌ្ឍបំណិនសង្គមរបស់ខ្លួន ។

សូមលើកទឹកចិត្តកូនអ្នកឱ្យចេះទទួលខុសត្រូវ និងមានម្ចាស់ការលើខ្លួនឯង ។







ជួយកុមារឱ្យដឹងនូវបំណិននានាដែលគេចេះហើយ និងវាមានតម្លៃ និងមានប្រយោជន៍ដល់សហគមន៍ ។ លើកទឹកចិត្តកុមារអភិវឌ្ឍបំណិនទាំងនេះឱ្យបានច្រើនថែមទៀត ។

## ជួយកូនឱ្យប្រាស្រ័យទាក់ទងអំពីអារម្មណ៍របស់ខ្លួន

កុមារដែលមិនអាចនិយាយអំពីអារម្មណ៍របស់ខ្លួន អាចមិនមានជំរើស ប៉ុន្តែត្រូវសំដែងអាកប្បកិរិយាទាំងនោះជំនួសវិញ ។ កុមារអាចវាយ ស្រែក និងធាក់នៅពេលធុញថប់ ឬខឹង ពីព្រោះកុមារគ្មានវិធីណាដែលអាចសំដែងអារម្មណ៍ទាំងនោះ ។ បើសិនជាកូនរបស់អ្នកមានអារម្មណ៍ធុញថប់ញឹកញាប់ ទ្រគោះបោះបោក ឬខឹងសម្បារ អ្នកត្រូវតែជួយកូនឱ្យចេះសំដែងអារម្មណ៍របស់ខ្លួនតាមរយៈមធ្យោបាយផ្សេងៗ ។

សម្លឹងមើលឱកាសនានាដែលអ្នកអាចបង្រៀនកូនអំពីសញ្ញា ឬពាក្យចំពោះការរំជួលចិត្តខ្លាំង។ ប្រការនេះនឹងជួយឱ្យក្មេងដឹង និងយល់អំពីការរំជួលចិត្តរបស់ខ្លួន។ នៅពេលក្មេងមានអារម្មណ៍បែបនេះ គេមានការងាយស្រួលធ្វើសញ្ញា ឬនិយាយប្រាប់អំពីការរំជួលចិត្ត ជាងការសំដែងចេញជាអាកប្បកិរិយា។




## ឱ្យរង្វាន់ចំពោះអាកប្បកិរិយាសមរម្យ

នៅពេលកុមារមានអាកប្បកិរិយាសមរម្យ មនុស្សនៅជុំវិញក៏ប្រព្រឹត្តអំពើល្អតបទៅក្មេងវិញដែរ។ នៅពេលកូនអ្នកមានអាកប្បកិរិយាល្អ ចូរសរសើរកូន។ កុមារម្នាក់ចង់បានសេចក្តីស្រឡាញ់ និងការអនុគ្រោះពីឪពុកម្តាយ និងមនុស្សឯទៀត ហើយកុមារនឹងធ្វើដដែលៗនូវអាកប្បកិរិយាទាំងឡាយណាដែលនាំមកនូវការសរសើរ និងការយកចិត្តទុកដាក់។ ការនិយាយសរសើរខ្លះៗនៅរៀងរាល់ពេលថ្ងៃ ឬឱបថើបដោយក្តីស្រឡាញ់ ឬក៏ឱ្យចំណីដែលកូនចូលចិត្តនឹងក្លាយជាផ្លូវដ៏វែងមួយទៅរកការលើកទឹកចិត្តចំពោះអាកប្បកិរិយាល្អៗ។

ការបង្រៀនកូនថ្លង់អំពីអាកប្បកិរិយាល្អៗ អ្នកត្រូវចេះអត់ធ្មត់ និងខិតខំយ៉ាងខ្លាំង។ ប៉ុន្តែនៅពេលណាកូនអភិវឌ្ឍបំណិនសង្គម និងមានអាកប្បកិរិយាល្អ វានឹងកាន់តែងាយស្រួលច្រើនសំរាប់ឱ្យកូនបង្កើតមិត្តភក្តិ ចូលរួមក្នុងសហគមន៍ និងទៅសាលារៀនទៀតផង។

- ចូរសរសើរពេលកូនធ្វើអ្វីមួយបានល្អ។




**ម្តាយ*ស៊ីស៊ី* លើកទឹកចិត្តនាង នៅពេលនាងព្យាយាមបោកខោអាវរបស់ខ្លួន។**

- ឱ្យរង្វាន់ចំពោះអាកប្បកិរិយាល្អៗដល់កូន ជាជាងអាកប្បកិរិយាមិនល្អ។ ផ្តល់ការញញឹមដល់កូន ឬអង្អែលដោយក្តីស្រឡាញ់នៅពេលអ្នកពេញចិត្តនឹងអាកប្បកិរិយារបស់កូន។



ជាញឹកញាប់ កុមារបន្តធ្វើអាកប្បកិរិយាមិនល្អ ពីព្រោះក្មេងបានដឹងថាអាកប្បកិរិយាមិនល្អនោះ នឹងជួយគេទាមទារឱ្យបានអ្វីៗដែលខ្លួនចង់បាន ។ ឧទាហរណ៍ ៈ-




**មិនយកចិត្តទុកដាក់ពេល*ក្វាមុី* មានអាកប្បកិរិយាទន់ភ្លន់...** | **ហើយផ្តល់ការយកចិត្តទុកដាក់ពេល*ក្វាមុី*ចាប់ផ្តើមស្រែកជំទាល...** | **លើកទឹកចិត្តចំពោះអាកប្បកិរិយាអាក្រក់ ។**

ប៉ុន្តែ បើសិនជាអ្នកផ្តល់ការយកចិត្តទុកដាក់ដល់កូន នៅពេលកូនមានអាកប្បកិរិយាទន់ភ្លន់ និងមិនយកចិត្តទុកដាក់ពេលកូនមានអាកប្បកិរិយាអាក្រក់ៗ នោះអ្នកបង្រៀនកូនថា ការសំដែងអាកប្បកិរិយាអាក្រក់មិនបណ្តាលឱ្យគេទទួលបានអ្វីមួយដែលគេចង់បាននោះទេ ។ ឧទាហរណ៍ម្តាយ*ក្វាមុី*បានដឹងថា ៈ-

**ផ្តល់ការយកចិត្តទុកដាក់ពេល*ក្វាមុី*មានអាកប្បកិរិយាទន់ភ្លន់...** | **តែកុំផ្តល់ការយកចិត្តទុកដាក់ពេល*ក្វាមុី*ស្រែកជំទាល...** | **លើកទឹកចិត្តចំពោះអាកប្បកិរិយាទន់ភ្លន់ ។**



## ប្រាប់កុមារឱ្យដឹងថា "ហេតុអ្វី?"

នៅពេលកុមារបានដឹងថា ហេតុអ្វីពួកគេគួរធ្វើកិច្ចការអ្នកបានស្នើ វាជាការងាយស្រួលសំរាប់ឱ្យកុមារធ្វើការងារនោះ។ ប៉ុន្តែ ដោយសារកុមារមិនអាចស្តាប់ឮល្អ នៅតូច គេអាចមិនទាន់ចេះពាក្យ ឬសញ្ញាបានគ្រប់គ្រាន់ដើម្បីយល់ថា "ហេតុអ្វី?" ជាញឹកញាប់ឪពុកម្តាយរកឃើញថា វាងាយស្រួលដោយគ្រាន់តែបង្គាប់កុមារឱ្យ**ធ្វើអ្វីមួយ** ជាងការពន្យល់ឱ្យកុមារដឹង។ បើសិនជាកុមារមិនយល់ថា ហេតុអ្វីពួកគេត្រូវធ្វើបែបនេះ កុមារអាចប្រែជាមានអារម្មណ៍តឹងតែងក្នុងចិត្ត។




***ហ៊ូវ៉ា*****អាចដើរបានលឿន បើសិនជាពុករបស់គេពន្យល់ប្រាប់ថា ដល់ពេលហូបអាហារល្ងាចនៅឯផ្ទះ!**

## ធ្វើការផ្លាស់ប្តូរឱ្យមានភាពងាយស្រួល

ការផ្លាស់ប្តូរ (ពីសកម្មភាពមួយទៅសកម្មភាពមួយទៀត) អាចមានការពិបាកចំពោះកុមារតូចៗភាគច្រើន។ ពួកគេអាចអាក់អន់ចិត្តពេលដូរពីផ្ទះមួយទៅផ្ទះមួយទៀត ឬក៏ត្រូវឈប់លេងកំសាន្ត ដើម្បីទៅងូតទឹក។ ពួកគេត្រូវតែទម្លាប់ផ្សាំខ្លួនទៅនឹងកិច្ចការប្រចាំថ្ងៃទាំងឡាយ។ ដរាបណាកុមាររៀនរំពឹងទុកនូវការផ្លាស់ប្តូរសកម្មភាពប្រចាំថ្ងៃជាបន្តបន្ទាប់ និងបានស៊ាំនឹងទម្លាប់បែបនេះ កុមារអាចពុះពារចំពោះសកម្មភាពធម្មតាប្រចាំថ្ងៃ។ នៅពេលពួកគេស៊ាំនឹងទម្លាប់មួយហើយ ទោះបីជាការផ្លាស់ប្តូរតូចមួយក៏ដោយ អាចធ្វើឱ្យកុមារគ្មានអារម្មណ៍កក់ក្តៅ។




នៅពេលកុមារដឹងថាមានអ្វីត្រូវរំពឹងទុក ពួកគេនឹងងាយស្រួលទទួលយកការផ្លាស់ប្តូរនោះ។ ពេលខ្លះរូបភាពអាចជួយអ្នកប្រាស្រ័យទាក់ទងអំពីការផ្លាស់ប្តូរបានល្អ។ ឧទាហរណ៍ បើសិនជាកូនកំពុងលេង ហើយត្រូវដល់ពេលកូនទៅងូតទឹក អ្នកអាចបង្ហាញរូបថតរបស់កូនដែលកំពុងងូតទឹក។ រៀបរាប់ពីអ្វីដែលរូបភាពពាក់ព័ន្ធនឹងការប្រាស្រ័យទាក់ទង អាចផ្តល់ពេលឱ្យកូនត្រៀមខ្លួនសំរាប់ការផ្លាស់ប្តូរ ហើយអាចធ្វើឱ្យការផ្លាស់ប្តូរកាន់តែងាយស្រួលសំរាប់អ្នកនិងកូន។

វាអាចជួយដល់អ្នក ដើម្បីឱ្យអ្នកមានការងាយស្រួលចេញទៅទីសាធារណៈ បើសិនជាអ្នកពន្យល់ប្រាប់កូនពីកន្លែងដែលអ្នកត្រូវទៅ មុនពេលអ្នកចាកចេញ។ ឧទាហរណ៍ បង្ហាញកន្ត្រកដល់កូនដើម្បីឱ្យគេយល់ថា អ្នកទៅផ្សារ។

**ចំណាំ :-** ការផ្លាស់ប្តូរនឹងកាន់តែងាយស្រួល ពេលកូនធំមានអាយុច្រើនបន្តិច។

## ជួយកូនឱ្យរៀនធ្វើការសំរេចចិត្ត

ចំណុចសំខាន់បំផុតដែលកុមារត្រូវការរៀន គឺរបៀបធ្វើការសំរេចចិត្តឱ្យបានល្អ។ បើអ្នក ឬបុគ្គលឯទៀតប្រាប់កុមារនូវអ្វីដែលត្រូវធ្វើគ្រប់ពេលវេលានោះ កុមារនឹងមិនចេះធ្វើការសំរេចចិត្តបានល្អឡើយ។




ការដែលអាចធ្វើការសំរេចចិត្តល្អ ជួយកុមារឱ្យមានទំនុកចិត្តលើខ្លួនឯង។ ការដែលមានទំនុកចិត្តជួយកុមារឱ្យចូលរួមយ៉ាងពេញលេញក្នុងសកម្មភាពនានានៃសហគមន៍របស់ពួកគេ និងជួយពួកគេឱ្យមានជីវិតរស់នៅប្រសើរឡើង។ នៅពេលណាក៏ដោយឱ្យតែអ្នកអាចធ្វើបាន ចូរលើកទឹកចិត្តកូនឱ្យធ្វើការសំរេចចិត្តនូវជំរើសសាមញ្ញៗ អំពីអ្វីដែលមានឥទ្ធិពលមកលើគេ។ ឧទាហរណ៍ ពេលខ្លះកុមារអាចសំរេចចិត្តរើសម្ហូបដែលខ្លួនចង់ហូប ឬភេសជ្ជៈដែលគេចង់ផឹក រើសសំលៀកបំពាក់ណាមួយដែលខ្លួនចង់ស្លៀកពាក់ ចូលដេកពេលណា ឬជ្រើសរើសអ្វីដែលត្រូវធ្វើ។ បើសិនជាកុមារថ្លង់ម្នាក់ចង់ធ្វើការសំរេចចិត្តតែមិនអាចប្រាប់អ្នកពីអ្វីដែលគេចង់បាន ឬចូលចិត្ត ចូរព្យាយាមសួរសំណួរដល់កុមារដើម្បីជួយក្មេងឱ្យប្រាស្រ័យទាក់ទងអំពីអ្វីដែលគេពេញចិត្តនឹងធ្វើ។

## មនុស្សគ្រប់គ្នាអាចជួយកុមារថ្លង់ឱ្យអភិវឌ្ឍបំណិនសង្គម

កុមារថ្លង់អាចរៀន និងហាត់បំណិនសង្គមរបស់ខ្លួនបានល្អបំផុត នៅពេលដែលពួកគេជាចំណែកមួយនៃសហគមន៍ដ៏កក់ក្តៅ និងនៅពេលដែលពួកគេបានទៅសាលារៀន។ នៅពេលកុមារបានឆ្លើយឆ្លង និងចំណាយពេលជជែកលេងជាមួយក្រុមមនុស្សនៃសង្គមក្រៅពីគ្រួសារផ្ទាល់របស់ខ្លួន ពួកគេបានផ្លោះចូលទៅក្នុងការអភិវឌ្ឍដ៏ធំនៃបំណិនសង្គម។ សហគមន៍ខ្លះមានមជ្ឈមណ្ឌលគាំពារកុមារនៅពេលថ្ងៃ ឬមត្តេយ្យសាលា ជាកន្លែងដែលក្រុមនៃកុមារទាំងឡាយរៀន និងលេងកំសាន្តជាមួយគ្នា។ កុមារយល់ថា ការរំពឹងទុកដែលបានបង្កើតឡើងនៅក្នុងក្រុមមួយ គឺមានភាពខុសគ្នា។ ពួកគេរៀនចែករំលែកផ្លាស់ប្តូរវេនគ្នា និងគិតអំពីអារម្មណ៍របស់អ្នកឯទៀត។

## ជួយកុមារថ្លង់រៀនអំពីព្រឹត្តិការណ៍ជុំវិញខ្លួនគេ

វាជាការសំខាន់ណាស់សំរាប់កុមារថ្លង់ ឬមិនអាចស្តាប់ឮល្អមានបទពិសោធន៍នៅក្នុងព្រឹត្តិការណ៍ទាំងឡាយរបស់សហគមន៍ ចូលរួមចំណែកក្នុងសកម្មភាពគ្រួសារ និងជជែករឿងហេតុទាំងនេះជាមួយមិត្តភ័ក្តិ និងក្រុមគ្រួសាររបស់ខ្លួន។ ឪពុកម្តាយ បងប្អូនស្រី និងប្រុស អាចជួយនាំកុមារថ្លង់ទៅលេងទីសាធារណៈឱ្យបានច្រើនតាមដែលអាចធ្វើបាន ហើយទៅលេងនឹងសាច់សាលោហិត និងមិត្តភ័ក្តិផងដែរ។ អ្នកត្រូវឆ្លៀតគ្រប់ឱកាសដើម្បីបង្រៀនកុមារថ្លង់អំពីអ្វីខ្លះដែលកើតឡើងនៅក្នុងសហគមន៍។

ចូរនាំកូនទៅជាមួយនៅពេលអ្នកទៅដងទឹក ទៅរកឧស ឬទៅផ្សារ ទៅសាលារៀន ទៅកន្លែងសក្ការៈបូជា ទៅពិធីបុណ្យកំសាន្ត ឬទៅប្រជុំក្នុងសហគមន៍ និងចូលរួមក្នុងព្រឹត្តិការណ៍នានា។ នៅតាមផ្លូវព្យាយាមសំគាល់អ្វីៗដែលកុមារស្តាប់ឮអាចរៀនដោយគ្រាន់តែប្រើការស្តាប់។ ព្យាយាមពន្យល់ប្រាប់កូននូវករណីទាំងនេះដោយប្រើការនិយាយពាក្យ ឬធ្វើសញ្ញាណាដែលអ្នកនិងកូនយល់។




**កុមារអាចរៀនអំពីព្រឹត្តិការណ៍ទាំងឡាយនៅជុំវិញខ្លួនតាមរយៈការមើលគេឯង។ ពួកគេអាចរៀនអ្វីៗទាំងឡាយ ដូចជានរណាជាអ្នកដាំដំណាំដែលគេបរិភោគ និងរបៀបដែលមនុស្សទិញ និងលក់ដូរនៅឯផ្សារ។**

## ជួយកូនឱ្យអភិវឌ្ឍចំណងមិត្តភាព

ខណៈដែលកុមារចាប់ផ្តើមលេងកំសាន្តទៅវិញទៅមកកាន់តែច្រើន ការប្រាស្រ័យទាក់ទង និងលទ្ធភាពប្រព្រឹត្តខ្លួនជាមួយកុមារដទៃ គឺកាន់តែសំខាន់ទៀត។ កុមារថ្លង់ភាគច្រើនតែងតែនៅដាច់ឆ្ងាយពីគេឯង និងមានអារម្មណ៍ឯកោ។ នេះគឺជាចំណែកមួយដោយសារពួកគេមិនបានរៀនបំណិនសង្គមឱ្យគ្រប់គ្រាន់ដើម្បីអភិវឌ្ឍចំណងមិត្តភាព។ វាក៏ដោយសារតែកុមារស្តាប់ឮ មិនដឹងពីរបៀបចូលរួមលេងកំសាន្តជាមួយកុមារថ្លង់ផងដែរ។




អ្នកអាចជួយកុមារស្តាប់ឮក្នុងសហគមន៍ ឱ្យពួកគេយល់ពីរបៀបប្រាស្រ័យទាក់ទងជាមួយកុមារថ្លង់។ នៅពេលកុមារឯទៀតបានដឹងពីរបៀបប្រាស្រ័យទាក់ទងជាមួយកុមារថ្លង់ កុមារស្តាប់ឮទាំងនោះអាចមានឆន្ទះឱ្យកុមារថ្លង់ចូលរួមនៅក្នុងការលេងកំសាន្តរបស់ពួកគេថែមទៀត។

ជាញឹកញាប់កុមារច្រើនតែប្រឌិតល្បែងលេង "តាំងខ្លួនជាតួអង្គណាមួយ"។ បើសិនជាពួកគេបញ្ចូលកុមារថ្លង់ម្នាក់ វាអាចជួយដល់ក្មេងថ្លង់រៀនអំពីអ្វីដែលរំពឹងទុកនៅក្នុងស្ថានភាពថ្មីៗ និងរៀនអំពីរបៀបសម្របអាកប្បកិរិយា។



**បងប្អូនប្រុសស្រីរបស់*សាយម៉ិន* កំពុងលេងតាំងខ្លួនជា "ម្ចាស់ហាង" ដើម្បីជួយ*សាយម៉ិន*ឱ្យយល់ពីរបៀបដែលមនុស្សប្រព្រឹត្តខ្លួននៅហាងលក់ដូរ និងរបៀបទិញរបស់របរ។**

ដើម្បីជួយកូនអ្នកឱ្យចេះបង្កើតមិត្តភ័ក្តិ និងលេងកំសាន្តជាមួយក្មេងឯទៀត សូមជួយកូនអ្នកឱ្យកាន់តែយល់ពីអារម្មណ៍របស់មនុស្សដទៃទៀត រៀនចែករំលែក និងសហការ ហើយយល់ពីវិន័យនានា។ កូនអាចត្រូវការឱ្យអ្នកជួយជ្រោមជ្រែងដើម្បីប្រាស្រ័យទាក់ទងជាមួយកុមារដទៃផងដែរ។




កុមារឯទៀតអាចទៅជាតឹងតែងចិត្តក្នុងការព្យាយាមលេងល្បែងជាមួយក្មេងម្នាក់ដែលមិនយល់អំពីវិន័យនៃល្បែងលេងរបស់ពួកគេ។ ពួកគេអាចចាប់ផ្តើមជន្មៀសក្មេងថ្លង់ចេញពីការលេងល្បែងនោះ។ អ្នកអាចជួយបង្ហាញកុមារស្តាប់ឮនូវវិធីលេងកំសាន្តនានា ដែលមិនត្រូវការពាក្យនិយាយ។ អ្នកអាចនិយាយពន្យល់អំពីវិន័យ និងបង្ហាញរបៀបលេងល្បែងដល់កូនរបស់អ្នក។

## "បំណិនសង្គម" របស់សហគមន៍

ខណៈពេលបង្រៀនបំណិនសង្គមដល់កុមារ គឺជាការសំខាន់ ប៉ុន្តែបំណិននោះមួយមុខគត់វាមិនគ្រប់គ្រាន់ទេ។ កុមារមិនត្រឹមតែរៀនបំណិនសង្គមតាមរបៀបដែលយើងបង្រៀនពួកគេ និងតាមរបៀបដែលយើងប្រព្រឹត្តខ្លួនចំពោះពួកគេប៉ុណ្ណឹងទេ ប៉ុន្តែកុមារក៏រៀនពីរបៀបដែលពួកគេឃើញមនុស្សម្នាប្រព្រឹត្តខ្លួនទៅវិញទៅមកនៅក្នុងសហគមន៍ដែរ។

នៅពេលយើងបង្រៀនកុមារឱ្យធ្វើជាមិត្តភ័ក្តិនឹងកុមារថ្លង់ និងរបៀបគោរពអ្នកដែលខុសប្លែកពីយើង យើងបានជួយកុមារឱ្យយល់ថា យើងឱ្យតម្លៃមេត្តាធម៌។ យើងបានបង្រៀនកុមារថា ការជួយដល់អ្នកឯទៀត គឺជាកាតព្វកិច្ចរបស់**មនុស្សគ្រប់ៗគ្នា**។



**នៅពេលយើងបង្រៀនកុមារឱ្យចេះលេងរួមគ្នាជាក្រុមមួយ យើងបានជួយពួកគេឱ្យយល់ថា យើងឱ្យតម្លៃនៃចំណងសាមគ្គីភាព និងកិច្ចសហការ។**

ប៉ុន្តែ យើងត្រូវតែយកគំនិតយោបល់របស់យើងទៅបង្កើតគំរូដោយសកម្មភាពផ្ទាល់របស់យើង! បើសិនជាកូនឃើញយើងមិនអើពើ ឬមិនរាប់រកមនុស្សឯទៀតដែលមានលទ្ធភាពខុសពីយើង ឬមើលទៅពួកគេមានសភាពខុសគ្នា ឬពួកគេជាអ្នកក្រខ្សត់ កូនយើងនឹងចេះមេរៀនមួយខុសគ្នាយ៉ាងខ្លាំងពីន័យដែលយើងបង្រៀនពួកគេ។

ពេលយើងទន់ភ្លន់ និងពោរពេញដោយការគោរពចំពោះអ្នកដទៃ កុមារដឹងថា នេះគឺជារបៀបដែលមនុស្សគួរប្រព្រឹត្តខ្លួនទៅវិញទៅមក។



បើយើងចង់ឱ្យកូនរៀនគោរពខ្លួនឯង និងអ្នកដទៃ យើងត្រូវតែយកតម្លៃទាំងនេះទៅអនុវត្តជាក់ស្តែងឱ្យកូនឃើញ។ យើងខ្លួនឯងត្រូវតែបង្ហាញការគោរពដល់មនុស្សដែលខុសប្លែកពីយើង។ យើងទាំងអស់គ្នាត្រូវតែខិតខំធ្វើការដើម្បីបង្កើតសហគមន៍មួយ ដែលស្វាគមន៍ហើយគាំទ្រមនុស្សគ្រប់ៗរូប និងប្រព្រឹត្តអំពើទាំងឡាយណាដែលមានសារៈសំខាន់ចំពោះយើង។